ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅ អនុវិទ្យាល័យក្នុងខេត្តតាកែវ

# Situations of teachers′ professional practices at secondary school in Takeo Province.


អៀក ចន្ធី

Euk Chanthy


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២១-២០២៣

**ក្រសួងអប់រំ យុវជន និងកីឡា**

Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅ អនុវិទ្យាល័យក្នុងខេត្តតាកែវ

## Situations of teachers´ professional practices at secondary school in Takeo Province.

**អៀក ចន្ធី**

Euk Chanthy

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល**

**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០២១-២០២៣**

| | | |
|---|---|---|
| **គ្រូដឹកនាំគោល** | ៖ | **បណ្ឌិត ឡឹយ សុភា** |
| **គ្រូដឹកនាំរង** | ៖ | **បណ្ឌិត ឈន ថន** |

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា “**ស្ថានភាពនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តតាកែវ**” សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំជំនាន់ទី១០ ពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបាន ស្រាវជ្រាវនិងចងក្រងដោយខ្ញុំបាទ ពិតប្រាកដមែន។

ថ្ងៃ ចន្ទ ១៣កើត ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ២០២៣

**ហត្ថលេខា**

**អៀក ចន្ធី**

# លិខិតបញ្ជាក់

| | |
|---|---|
| **បណ្ឌិត ឡឹយ សុគា** | ជាគ្រូដឹកនាំគោល |
| **បណ្ឌិត ឈន ថន** | ជាគ្រូដឹកនាំរង |

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **អៀក ចន្ធី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវស្ដីពី“**ស្ថានភាពនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅក្នុងខេត្តតាកែវ**” ពិតប្រាកដមែន។

ថ្ងៃ ចន្ទ ១៣កើត ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣

| | |
|---|---|
| ........................................ | ........................................ |
| **បណ្ឌិត ឡឹយ សុគា** | **បណ្ឌិត ឈន ថន** |
| គ្រូឧទ្ទេស វិទ្យាស្ថានជាតិអប់រំ | គ្រូឧទ្ទេស វិទ្យាស្ថានជាតិអប់រំ |

# លិខិតថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះលោកឳពុកអ្នកម្ដាយ ដែលបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ទំនុកបំរុងដល់រូបកូនឱ្យបានទទួលការសិក្សារហូតរូបកូនមានថ្ងៃនេះ និងសូមថ្លែងអំណរគុណយ៉ាងច្រើនបំផុតដល់ឧត្តមភរិយាជាទីស្រឡាញ់របស់ខ្ញុំ និងមិត្តភក្តិ ដែលបានគាំទ្រ និងលើកទឹកចិត្តក្នុងពេលសិក្សានេះ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះគណៈកម្មការគ្រប់គ្រងការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃបំផុត មកបង្ហាត់បង្រៀន និងពន្យល់គ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នា។ ជាពិសេសខ្ញុំបាទសូមគោរពថ្លែងអំណរគុណជូនចំពោះអ្នកគ្រូបណ្ឌិត **ឡឹយ សុគា** សាស្ត្រាចារ្យដឹកនាំសរសេរនិក្ខេបបទ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការពិនិត្យវាយតម្លៃ ជួយណែនាំ និងផ្ដល់យោបល់ណែនាំដល់រូបខ្ញុំបាទក្នុងការសរសេរនិក្ខេបបទស្ដីពី"**ស្ថានភាពនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យខេត្តតាកែវ**"។ ខ្ញុំបាទសូមថ្លែងអំណរគុណដល់បណ្ឌិត **ឈុន ថន** សាស្ត្រាចារ្យដឹកនាំរង ដែលតែងតែផ្ដល់នូវកម្លាំងចិត្ត ចំណេះដឹងចែករំលែកបទពិសោធដល់រូបខ្ញុំ ព្រមទាំងមិត្តរួមថ្នាក់ជំនាន់ទី១០ និងមិត្តរួមការងារដែលតែងតែផ្ដល់នូវកម្លាំងចិត្ត ធ្វើឱ្យរូបខ្ញុំទទួលបានជោគជ័យនាថ្ងៃនេះ។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំមន្ទីរ គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ នៃមន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ តាមសាលាគោលដៅទាំងអស់ដែលបានអនុញ្ញាត និងចូលរួមសហការធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធពរជ័យ ជូនចំពោះឯកឧត្តម លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តរួមជំនាន់ទាំងអស់ សូមទទួលបាននូវព្រះពុទ្ធពរទាំង៤ប្រការ គឺ **អាយុ វណ្ណៈ សុខៈ និងពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# មូលន័យសង្ខេប

ការស្រាវជ្រាវនេះ បានសិក្សាអំពីការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅអនុវិទ្យាល័យ ដើម្បីកែលម្អប្រព័ន្ធអប់រំ និងធានាគុណភាពអប់រំសម្រាប់ការរក្សាស្ថេរភាព និងអភិវឌ្ឍសង្គមជាតិ។ គ្រូបង្រៀនជាកត្តាសំខាន់ក្នុងការរួមចំណែកលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពអប់រំ។ ការសិក្សានេះ មានគោលបំណងសិក្សា និងឈ្វេងយល់ពីទស្សន ការប្រតិបត្តិ និងបញ្ហាប្រឈមនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ។ ការសិក្សានេះ បានប្រើវិធីសាស្ត្រស្រាវជ្រាវចម្រុះ ដែលរួមបញ្ចូលនៃវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ និងបរិមាណវិស័យ។ ទិន្នន័យនៃការស្រាវជ្រាវនេះ ជាប្រភេទទិន្នន័យប្រមូលថ្មី ដោយកម្រងសំណួរ និងសម្ភាសន៍ផ្ទាល់។ ការសិក្សានេះ បានប្រើប្រាស់វិធីសាស្ត្រវិភាគទិន្នន័យខ្លឹមសារ និងពណ៌នាស្ថិតិ។ ទិន្នន័យដែលបានប្រមូល ត្រូវបានបញ្ចូលទៅក្នុងកម្មវិធី Excel ដើម្បីបង្កើតជាគំនូសតាងជាក្រាបហ្វិក និងភាគរយ ដើម្បីធ្វើការសន្និដ្ឋាន និងវាយតម្លៃលើលទ្ធផលស្រាវជ្រាវ។ លទ្ធផលស្រាវជ្រាវបង្ហាញថា ការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ បានរួមចំណែកក្នុងការលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ការធានាការអនុវត្តគោលនយោបាយអប់រំប្រកដោយគុណភាព និងប្រសិទ្ធភាព និងការលើកកម្ពស់គុណភាពអប់រំ។ ការសិក្សានេះ បានផ្តល់នូវសារៈសំខាន់ជាច្រើន រួមមាន(១)ការលើកកម្ពស់ការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀន (២) ការអភិវឌ្ឍគុណវុឌ្ឍិគ្រូបង្រៀន និង(៣) ការធ្វើកំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀន។

# Abstract

This research examined the professional practice of secondary school teachers to improve the education system and ensure the quality of education for the stability and development of the society. Teachers were a vital factor in contributing to the efficiency and quality of education. This study aimed to study and understand the concepts, practices, and challenges of professional practice of teachers in lower secondary schools. This study used the mixed research-methods that included qualitative and quantitative research methods. The data of this research were primary data collected by using the questionnaires and face-to-face interviews. This study employed the content and descriptive statistics analysis methods. The collected data were computed into the Microsoft Excel to create the tables, graphical charts, and percentages to conclude and evaluate the research results. The results showed that the teachers' professional practice at the lower secondary schools contributed to the enhancement of use of technological information, ensuring the implementation of education policies with the quality and effectiveness, and improving the quality of education. This study provided the significant contributions, including (1) improving the professional practice of teachers, (2) developing the teacher qualifications, and (3) reforming teacher training.

# អក្សរកាត់

| | | |
|---|---|---|
| ក្រសួងអយក | : | ក្រសួងអប់រំ យុវជន និងកីឡា |
| **វ.ស.ក** | : | វិទ្យាស្ថានសភាកម្ពុជា |

**មាតិកា**

**សេចក្តីអះអាងរបស់បេក្ខជន** ........ I
**លិខិតបញ្ជាក់** ........ II
**លិខិតថ្លែងអំណរគុណ** ........ III
**មូលន័យសង្ខេប** ........ IV
ABSTRACT ........ V
**អក្សរកាត់** ........ VI
**ជំពូក ១** ........ 1
**សេចក្តីផ្តើម** ........ 1
១.១. លំនាំនៃការស្រាវជ្រាវ ........ 1
១.២. បញ្ហានៃការស្រាវជ្រាវ ........ 2
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ 5
១.៤ សំណួរនៃការស្រាវជ្រាវ ........ 5
១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ........ 5
១.៦ ដែនកំណត់នៃការស្រាវជ្រាវ ........ 5
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 6
**ជំពូក ២** ........ 7
**រំលឹកទ្រឹស្តី** ........ 7
២.១ និយមន័យនៃពាក្យគន្លឹះ ........ 7
២.១.១ វិជ្ជាជីវៈ ........ 7
២.១.២ គ្រូបង្រៀន ........ 7
២.១.៣ វិជ្ជាជីវៈគ្រូបង្រៀន ........ 8
២.២ ចំណេះដឹង និងការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀន ........ 9
២.៣ ការសិក្សាវិជ្ជាជីវៈគ្រូបង្រៀន ........ 12
២.៤ សីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ........ 14
**ជំពូក ៣** ........ 16
**វិធីសាស្រ្តស្រាវជ្រាវ** ........ 16

៣.១ ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ ....................................................16
៣.២ ការជ្រើសរើសសំណាក ....................................................16
៣.៣ ប្រភពទិន្នន័យ ....................................................17
៣.៤ វិធីសាស្ត្រប្រមូលទិន្នន័យ ....................................................18
៣.៤.១ សម្ភាសផ្ទាល់ ....................................................18
៣.៤.២ កម្រងសំណួរ ....................................................18
៣.៤.៣ កម្រិតចង្អុលបង្ហាញ ....................................................18
៣.៥ វិធីសាស្ត្រវិភាគទិន្នន័យ ....................................................19
៣.៥.១ ការវិភាគសម្ភាសផ្ទាល់ ....................................................19
៣.៥.២ ការវិភាគកម្រងសំណួរ ....................................................19
៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ ....................................................20
**ជំពូក ៤** ....................................................21
**លទ្ធផលស្រាវជ្រាវ និងការពិភាក្សា** ....................................................21
៤.១ លទ្ធផលនៃការស្រាវជ្រាវ ....................................................21
៤.១.១ សិក្សាពីទស្សនគ្រូបង្រៀនចំពោះការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ ....................................................21
៤.១.២ សិក្សាពីកម្រិតនៃការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ ....................................................25
៤.២ ការពិភាក្សា ....................................................36
៤.២.១ ការអភិវឌ្ឍចំណេះដឹងវិជ្ជាជីវៈគ្រូបង្រៀន ....................................................36
៤.២.២ ប្រសិទ្ធភាពនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀន ....................................................37
៤.២.៣ ស្វ័យសិក្សាវិជ្ជាជីវៈគ្រូបង្រៀន ....................................................38
**ជំពូក ៥** ....................................................40
**សេចក្តីសន្និដ្ឋាន និងសំណូមពរ** ....................................................40
៥.១. សេចក្តីសន្និដ្ឋាន ....................................................40
៥.២. អនុសាសន៍ ....................................................40
៥.២.១. ការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព ....................................................41
៥.២.២. គុណប្រយោជន៍នៃការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀន ....................................................41
៥.៣. សំណូមពរ ....................................................41

**ឯកសារយោង** ........................................................................................................ 43
**ឧបសម្ព័ន្ធ** ............................................................................................................ 45

# ជំពូក ១
# សេចក្តីផ្តើម

## ១.១. លំនាំនៃការស្រាវជ្រាវ

ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពសម្រាប់បម្រើសេចក្តីត្រូវការប្រទេសជាតិ មិនអាចកាត់ផ្តាច់ចេញពីការអប់រំបានឡើយ។ វិស័យអប់រំរីកចម្រើន និងមានប្រសិទ្ធភាព គុណភាពទាមទារជាចាំបាច់នូវកម្រិតសមត្ថភាពគ្រូបង្រៀនដែលក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងយកចិត្តទុកដាក់ជាប្រចាំ។ ដើម្បីឆ្លើយតបនឹងបរិបទនេះ និងបរិបទសកលភាវូបនិយកម្ម ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំគោលនយោបាយស្តីគ្រូបង្រៀនក្នុងគោលបំណងកំណត់យុទ្ធសាស្ត្រដើម្បីអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវស្របតាមការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀនផ្តល់លក្ខខណ្ឌចាំបាច់ក្នុងការបំពេញការងារ ប្រកបដោយប្រសិទ្ធិភាពនិងសក្តិសិទ្ធិ និងមានការទទួលស្គាល់ពីសង្គម(ក្រសួងអប់រំ យុវជន និងកីឡា (២០១៣) ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអប់រំ ទំព័រទី១) ។

ជាការពិត ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ វិស័យអប់រំ ក៏ដូចវិស័យផ្សេងៗទៀតត្រូវបានបំផ្លិចបំផ្លាញដល់កម្រិតសូន្យទាំងធនធានមនុស្សទាំងមូលដ្ឋានសម្ភារបរិក្ខា។ នៅថ្ងៃទី២៦ មករា ១៩៨០ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានបង្កើតឡើងវិញ សាលារៀនគ្រប់កម្រិតសិក្សាទូទាំងប្រទេសត្រូវបានចាប់ផ្តើមទទួលសិស្សានុសិស្សឱ្យចូលរៀនវិញ ព្រមទាំងសាលាបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនក៏ត្រូវបានចាប់ផ្តើមដំណើរការជាបន្តបន្ទាប់ដោយនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការជាអ្នកទទួលខុសត្រូវ។ ក្នុងស្ថានភាពដ៏លំបាកនេះ ការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនត្រូវបានចាប់ផ្តើមពីការប្រមូលអតីតគ្រូបង្រៀន សិស្ស និស្សិត និងអ្នកមានកម្រិតវប្បធម៌មួយចំនួនដែលនៅសេសសល់ពីរបបកម្ពុជាប្រជាធិបតេយ្យមកបណ្តុះបណ្តាល ចិត្ត-គរុកោសល្យ នៅវិក្រឹត្យការរាជធានី-ខេត្តទាំង១៨ រួចបញ្ជូនទៅកាន់សាលាចំណោះទូទៅនៅទូទាំងប្រទេសកម្ពុជា (ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ទំព័រទី១ - ២)។

ចាប់ពីឆ្នាំ១៩៨៣ ក្រសួងអប់រំបានសម្រេចឱ្យសាលាគរុកោសល្យ និងវិក្រឹត្យការរាជធានីខេត្តទាំង ១៨ និងសាលាមធ្យមសិក្សាគរុកោសល្យ មត្តេយ្យមជ្ឈឹម បណ្ដុះបណ្ដាលគ្រូបង្រៀនបឋមសិក្សា និង មតេយ្យសិក្សារយៈពេលវែងដោយចាប់ផ្ដើមពីរូបមន្ត ៧+១ រហូតដល់ ១២+២ សម្រាប់ខេត្តវាលរាប។ ដោយឡែកសម្រាប់ខេត្តភូមិភាគព្រៃសាន កោះកុង និងតំបន់ដាច់ស្រយាលមួយចំនួន ការបណ្ដុះបណ្ដាល គ្រូបឋមសិក្សាត្រូវបានចាប់ផ្ដើមពីរូបមន្ត ៣+១ និងបច្ចុប្បន្ន ៩+២ និង ១២+២។ នៅឆ្នាំ១៩៨៤ មជ្ឈមណ្ឌល គរុកោសល្យភូមិភាគចំនួន៦ត្រូវបានបង្កើតឡើង សម្រាប់បណ្ដុះបណ្ដាលគ្រូមធ្យមសិក្សា បឋមភូមិដោយចាប់ផ្ដើមពីរូបមន្ត ៧+៣ រហូតបច្ចុប្បន្ន ១២+២។

ចំពោះការបណ្ដុះបណ្ដាលគ្រូបង្រៀននៅកម្រិតឧត្ដម បានចាប់ផ្ដើមពីឆ្នាំសិក្សា ១៩៨០-១៩៨១ នៅសាលាគរុវិជ្ជាជាន់ខ្ពស់ "បច្ចុប្បន្នជាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ" ដោយចាប់ផ្ដើមពីការបណ្ដុះបណ្ដាល រយៈពេល ៤ ខែ ៧ ខែ ១០+៣ ១០+៤ និងបរិញ្ញាបត្រ+១ ដែលកំពុងបន្តបណ្ដុះបណ្ដាលនៅវិទ្យាស្ថាន ជាតិអប់រំរហូតដល់បច្ចុប្បន្ន (ក្រសួងអប់រំ យុវជន និងកីឡា(២០១៦) ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ទំព័រទី១-២)។

ក្នុងស្ថានភាពបែបនេះ យើងឃើញថាគុណភាពនៃការអប់រំមានការប្រែប្រួលមួយកម្រិតគួរឲ្យកត់ សម្គាល់ដើម្បីឱ្យការងារបណ្ដុះបណ្ដាល និងវិក្រឹតការគ្រូបង្រៀនមានកម្មវិធី និងទិសដៅច្បាស់លាស់ ដោយធានាបានគុណភាពសមស្រប ទើបក្រសួងបានកសាងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននេះឡើងក្នុងគោល បំណងធ្វើឲ្យគ្រូបង្រៀនមានសមត្ថភាពដល់ស្តង់ដាមួយសមស្របប្រហាក់ប្រហែល និងគ្រូបង្រៀនក្នុងតំបន់ (ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ទំព័រទី១-២)។

## ១.២. បញ្ហានៃការស្រាវជ្រាវ

ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងយកចិត្តទុកដាក់ធ្វើកំណែទម្រង់វិស័យអប់រំដោយ ផ្តោតទៅលើការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀន ដើម្បីធ្វើឱ្យវិស័យអប់រំមានការរីកចម្រើន និងមានសក្តានុភាព នៅទូទាំងប្រទេស។ ការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀនសំដៅលើការយល់ដឹងពីតួនាទី ភារកិច្ច កាតព្វកិច្ច និង ករណីកិច្ចរបស់គ្រូបង្រៀនក្នុងការអនុវត្តអាជីពឱ្យសមស្របដោយផ្អែកលើផ្នែកបទដ្ឋានគតិយុត្ត បទប្បញ្ញត្តិ បទបញ្ជា និងលិខិតគតិយុត្តផ្សេងៗ ដើម្បីស្ថាបនាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់គ្រប់ដណ្ដប់វិសាលភាព

ទៅលើជនទាំងឡាយណាដែលកំពុងប្រកបវិជ្ជាជីវៈជាគ្រូបង្រៀននៅព្រះរាជាណាចក្រកម្ពុជា ដូចដែលបានចែងក្នុងអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន(រាជរដ្ឋាភិបាល (២០០៨) អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈ ទំព័រទី៤) ។ យោងទៅតាមរបាយការណ៍សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យបានបង្ហាញលទ្ធផលនៃការអង្កេតថ្នាក់ជាតិទៅលើវិស័យអប់រំនៅឆ្នាំ២០១១ ចំនួន១៧ ខេត្ត ក្រុង បានរកឃើញបញ្ហាធំៗមួយចំនួន ដែលគ្រូបង្រៀននៅទូទាំងប្រទេសកំពុងជួប គឺបញ្ហាប្រាក់ខែ អំពើលុករលួយ ខ្វះខាតការផ្គត់ផ្គង់ ការបណ្តុះបណ្តាល និងសម្ភារៈសិក្សា។ តាមរបាយការណ៍របស់គ្រូបង្រៀនកម្ពុជាឯករាជ្យកាលពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០១១ បានសរសេរថា លោកគ្រូ អ្នកគ្រូជាង៧០០នាក់នៅចំនួន១៧ ខេត្ត ក្រុង បានឆ្លើយតបទៅនឹងកម្រងសំណួរបិទ និងសំណួរបើកនៃការអង្កេត។ លទ្ធផលនៃការអង្កេតបានបង្ហាញថា មានគ្រូចំនួន ៨៥% មិនបានចូលរួមធ្វើការសម្រេចចិត្តនៅក្នុងសាលារបស់ពួកគេ និងមិនទទួលបានព័ត៌មានបង្ហាញពីរបាយការណ៍ហិរញ្ញវត្ថុបានច្បាស់លាស់ឡើយ។ ៤៥% គ្រូមិនធ្លាប់បានឮគោលនយោបាយអប់រំរបស់ក្រសួងអប់រំ ៤៥% គិតថា គ្មានការអភិវឌ្ឍទៅលើវិស័យអប់រំ និង ៣៩% គិតថាវិស័យអប់រំធ្លាក់ចុះ (សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ (២០១១) របាយការណ៍ស្តីពីគ្រូបង្រៀន ទំព័រទី១០)។

ស្របជាមួយគ្នានេះ របាយការណ៍របស់អង្គការ UNESCO បានបង្ហាញលទ្ធផលនៃការសិក្សាស្រាវជ្រាវស្តីពីបញ្ហាប្រឈមរបស់គ្រូបង្រៀនចំនួន ៤៧៣៩ នាក់ ដែលទើបតែជ្រើសរើសឱ្យបម្រើការនៅតាមអង្គភាពក្រោមចំណុះក្រសួងអប់រំ យុវជន និងកីឡា។ របាយការណ៍នេះ បានរកឃើញបញ្ហាធំចំនួន៣ រួមមាន៖ ទី១. គ្រូបង្រៀនទទួលប្រាក់ខែតិច(ជាមធ្យមប្រាក់ខែគ្រូ ៣០០ រយដុលារ) ក្នុងមួយខែ ដូច្នេះហើយពួកគេមិនអាចចញ្ចឹមជីវិតបាន គឺវាគ្រាន់តែបានផ្គត់ផ្គង់បានមួយផ្នែកនៃការរស់នៅប្រចាំថ្ងៃតែប៉ុណ្ណោះ។ ទី២.ដោយសារតែនៅជនបទមានកង្វះខាតកន្លែងស្នាក់នៅសម្រាប់គ្រូបង្រៀន ហើយលំបាកក្នុងការធ្វើដំណើរនិងខ្វះសម្ភារប្រើប្រាស់មួយចំនួនទៀត និង ទី៣. ដោយសារតែពួកគេត្រូវចំណាយថវិកាច្រើនក្នុងការរស់នៅដូចជា ជួលផ្ទះ គ្រឿងឧបភោគបរិភោគ និងថ្នាំពេទ្យសម្រាប់ព្យាបាលជំងឺ ឧបករណ៍

បង្រៀន និងមធ្យោបាយធ្វើដំណើរ( UNESCO (២០១៤) របាយការណ៍គ្រូបង្រៀន ទំព័រទី៨) ។

យោងតាមរបាយការណ៍របស់អង្គការ UNESCO នៅឆ្នាំ២០១៥ ធ្លាប់បានបង្ហាញផងដែរថា កង្វះខាតកន្លែងស្នាក់ នៅសម្រាប់គ្រូបង្រៀនក៏ជាមូលហេតុប្រឈមសំខាន់មួយដែលធ្វើឱ្យមានការខ្វះខាតគ្រូបង្រៀន ជាពិសេសនៅតំបន់ដាច់ស្រយាលនៅកម្ពុជា។ អង្គការ UNESCO បានបញ្ជាក់ថា ចំណុចនេះធ្វើឱ្យគ្រូបង្រៀនមួយចំនួនធំមិនព្រមទៅបង្រៀននៅតំបន់ដាច់ស្រយាលដែលជាហេតុធ្វើឱ្យការអប់រំនៅតាមតំបន់ជនបទនៅមានកម្រិតអន់ថយ ( UNESCO (២០១៥) របាយការណ៍គ្រូបង្រៀន ទំព័រទី១១) ។

នៅខែកក្កដា ឆ្នាំ២០១៧ របាយការណ៍ស្រាវជ្រាវរបស់វិទ្យាស្ថានសភាកម្ពុជា(វ.ស.ក)បានរកឃើញបញ្ហាប្រឈមរបស់គ្រូបង្រៀននៅខេត្តព្រះវិហារ ឧត្តរមានជ័យ និងបន្ទាយមានជ័យ។ បញ្ហាប្រឈមទាំងនោះរួមមាន កង្វះខាតគ្រូបង្រៀន និងអាគារសិក្សា ហេដ្ឋារចនាសម្ព័ន្ធដូចជា ប្រព័ន្ធទឹក បន្ទប់ទឹក និងសមាមាត្រសិស្សធៀប និងគ្រូបង្រៀនខ្ពស់ បញ្ហាសិស្ស ភាពក្រីក្រ។ល។ ជាងនេះ ថ្វីបើមានការកើនឡើងនៃចំនួនគ្រូបង្រៀននៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សា នៅឆ្នាំ ២០១៦ មានចំនួន ៤៤.៨៨៤ នាក់ និង ៤០.៩២៤នាក់ក៏នៅតែមានការខ្វះខាតគ្រូ។ ក្នុងចំណោមគ្រូបង្រៀននៅកម្រិតបឋមសិក្សាទាំងអស់ គ្រូបង្រៀនប្រហែលជា ៣0% មានការអប់រំកម្រិតអនុវិទ្យាល័យ ឬទាបជាងអនុវិទ្យាល័យ។ ក្នុងចំណោមគ្រូថ្នាក់អនុវិទ្យាល័យទាំងអស់ គ្រូបង្រៀនប្រហែល ៥0% មានការអប់រំកម្រិតវិទ្យាល័យ ប្រហែលជា ១៤% មានការអប់រំកម្រិតអនុវិទ្យាល័យ និង 0,៧0% មានកម្រិតអប់រំបឋមសិក្សា។ ហេតុដូច្នេះហើយ ការអប់រំនិងវិធីសាស្រ្តបង្រៀនរបស់គ្រូបង្រៀនមួយចំនួននៅមានកម្រិតនៅឡើយ (វិទ្យាស្ថានសភាកម្ពុជា (២០១៧) របាយការណ៍ស្រាវជ្រាវស្តីពីគ្រូបង្រៀន ទំព័រទី៩) ។

តាមរយៈរបាយការណ៍សិក្សាស្រាវជ្រាវបានបង្ហាញឱ្យឃើញនូវបញ្ហាប្រឈម និងសូចនាករដែលពាក់ព័ន្ធទៅនិងការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀនទើប អ្នកសិក្សាស្រាវជ្រាវជ្រើសរើសប្រធានបទស្តីពី "**ស្ថានភាពនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅកម្រិតអនុវិទ្យាល័យ**" ដើម្បីសិក្សាពីទស្សន កម្រិតនៃការអនុវត្ត និងបញ្ហាប្រឈមរបស់គ្រូបង្រៀនមកធ្វើការវិភាគ និងបកស្រាយលទ្ធផលដែលទទួលបាន ដើម្បីជា

ភស្តុតាងសម្រាប់ធ្វើការពិនិត្យតាមដាន និងវាយតម្លៃសម្រាប់ការអនុវត្តនៅឆ្នាំសិក្សាបន្តបន្ទាប់ឱ្យកាន់តែប្រសើរឡើង។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះផ្តោតលើចំណុចសំខាន់ចំនួនពីរដូចខាងក្រោម៖

១. សិក្សាពីទស្សននិងកម្រិតការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ

២. កម្រិតពីបញ្ហាប្រឈមនៃការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ

## ១.៤ សំណួរនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងវត្ថុបំណងនៃការស្រាវជ្រាវខាងលើ អ្នកស្រាវជ្រាវបានបង្កើតសំណួរស្រាវជ្រាវចំនួនបី រួមមាន៖

១.តើគ្រូបង្រៀនមានទស្សនៈបែបណាចំពោះការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ?

២.តើគ្រូបង្រៀនមានការយល់ដឹងកម្រិតណាពីការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋភូមិ?

៣.តើកត្តាអ្វីខ្លះដែលជាបញ្ហាប្រឈមនៃការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះបានផ្តល់នូវសារៈសំខាន់ជាច្រើន រួមមានៈ(១)ការជួយលើកកម្ពស់ការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀន (២) ការអភិវឌ្ឍគុណវុឌ្ឍិគ្រូបង្រៀន និង(៣) ការធ្វើកំណែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀន ។

## ១.៦ ដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីឱ្យការសិក្សាស្រាវជ្រាវមានដំណើរការទៅបានល្អ និងវិភាគបានគ្រប់ជ្រុងជ្រោយលើប្រធានបទ "**ស្ថានភាពនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅកម្រិតអនុវិទ្យាល័យខេត្តតាកែវ**" ការសិក្សានេះ ផ្តោតទៅលើលោកគ្រូ-អ្នកគ្រូដែលកំពុងបំរើការនៅអនុវិទ្យាល័យសាធារណៈមួយចំនួនស្ថិតនៅខេត្តតាកែវ។ ចំនួនសំណាកដែលបានប្រើសម្រាប់ការសិក្សានេះ មានកម្រិត និងមិនគ្របដណ្តប់ទូទាំងប្រទេសឡើយ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែងចែកជា ៥ជំពូក។ **ជំពូក១ បង្ហាញពីសេចក្តីផ្តើម រួមមាន៖** លំនាំបញ្ហានៃការស្រាវជ្រាវ បញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។ **ជំពូក២ រំលឹកទ្រឹស្តី៖** គឺពន្យល់បកស្រាយពីទ្រឹស្តីដែលពាក់ព័ន្ធ និងការពារអំណះអំណាននៃការសរសេរនិក្ខេបបទដោយយកទ្រឹស្តីរបស់អ្នកប្រាជ្ញ លិខិតបទដ្ឋានគតិយុត្តសំខាន់ៗ និងឯកសារផ្សេងៗដែលពាក់ព័ន្ធទៅនឹងការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀន។ **ជំពូក៣ បង្ហាញពីវិធីសាស្ត្រស្រាវជ្រាវ រួមមាន៖** ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ (វិធីសាស្ត្រស្រាវជ្រាវ និងឧបករណ៍ស្រាវជ្រាវ) សំណាកគំរូ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីសាស្ត្រវិភាគទិន្នន័យ និងក្រមសីលធម៌នៃការស្រាវជ្រាវ។ **ជំពូក៤ លទ្ធផលស្រាវជ្រាវនិងការពិភាក្សា៖** ពិភាក្សាទៅលើទស្សនៈគ្រូបង្រៀនចំពោះការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀន និងឈ្វេងយល់ពីការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូបង្រៀន និងកម្រិតពីបញ្ហាប្រឈមនៃការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ។ **ជំពូក៥** សេចក្តីសន្និដ្ឋាន និងអនុសាសន៍។ បង្ហាញសន្និដ្ឋានលើគ្រប់ចំណុចដែលបានវិភាគផ្តល់ជាយោបល់ទៅលើចំណុចដែលត្រូវកែលំអ និងសំណូមពរដល់អ្នកសិក្សាស្រាវជ្រាវបន្ត។

# ជំពូក ២
# រំលឹកទ្រឹស្តី

## ២.១ និយមន័យនៃពាក្យគន្លឹះ

### ២.១.១ វិជ្ជាជីវៈ

**វិជ្ជាជីវៈ** សំដៅលើមុខតំណែង ឬមុខរបរសម្រាប់ចិញ្ចឹមជីវិត(វចនានុក្រមខ្មែរ(១៩៦៨)។ លោក Jennifer បានលើកឡើងថាវិជ្ជាជីវៈគឺជាប្រភេទនៃមុខរបរដែលមានធាតុផ្សំចំនួន៣រួមមានៈ ១). វាជាមុខរបរឆ្លើយតបទៅនឹងផ្នែកសំខាន់ៗមួយចំនួននៃតម្រូវការរបស់មនុស្ស ២). វាជាកិច្ចសន្យាការងារកំណត់តែនៃកំឡុងពេលបំពេញភារកិច្ច - ភារកិច្ចដែលជារឿយៗដែលមាន ទាក់ទងនឹងឧត្តមគតិនៃសេវាកម្មជាក់លាក់ ៣). មនុស្សម្នាក់ក្លាយជាសមាជិកនៃសហគមន៍អ្នកប្រតិបត្តិដែលលះបង់ដល់បុព្វហេតុរួមជាមួយនឹងកាតព្វកិច្ចដើម្បីប្រព្រឹត្តតាម និងបន្តជាទំលាប់ (Jennifer (2017) Challenges facing the Implementation of teacher ទំព័រទី៣៤)។ លើសពីនេះ លោក Jack ក៏បានកំណត់ថាវិជ្ជាជីវៈគឺសំដៅដល់រយៈពេលនៃការអប់រំឬការបណ្តុះបណ្តាលមុនពេលបំពេញភារកិច្ចជាផ្លូវកា(Jack (2018) Teacher professional Development ទំព័រទី២៥)។ យោងទៅតាមវចនានុក្រមអង់គ្លេសបានកំណត់ថាវិជ្ជាជីវៈ គឺជាអាជីពដែលទាមទារចំណេះដឹងឯកទេស ហើយជារឿយៗ ការរៀបចំការសិក្សាដែលមានរយៈវែង និងមានមូលដ្ឋានគ្រឹះត្រឹមត្រូវ (Webster (2014) The Merriam-Webster Dictionary ទំព័រទី៦)។

ផ្តើមចេញពីទ្រឹស្តីអ្នកប្រាជ្ញបានបកស្រាយអំពីវិជ្ជាជីវៈខាងលើ និងទស្សនដែលបានលើកឡើងក្នុងការសិក្សានេះ វិជ្ជាជីវៈសំដៅទៅលើអ្នកដែលអនុវត្តវិជ្ជាជីវៈពោលគឺអ្នកដែលធ្វើការក្នុងវិស័យការងារជាក់លាក់ ជំនាញ នឹងចំណេះដឹងរបស់គាត់ដែលបានទទួលតាមរយៈការបង្រៀននៅតាមសាលានានា។

### ២.១.២ គ្រូបង្រៀន

**គ្រូបង្រៀន** គឺសំដៅលើអ្នកមានចិត្តធ្ងន់និងគួរឱ្យគោរព និងជាអ្នកបង្ហាត់បង្រៀនចំណេះដឹងវិជ្ជាសិល្បសាស្រ្តផ្សេងៗដល់សិស្ស(វចនានុក្រមខ្មែរ (១៩៦៨) ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិតទំព័រទី១៥)។ គ្រូបង្រៀន សំដៅអ្នកដែលផ្តល់ការអប់រំទូន្មាន បង្ហាត់បង្ហាញ ផ្តល់ចំណេះដឹង និងចំណេះធ្វើដល់

សិស្សានុសិស្ស (វាចនានុក្រមខ្មែរ(២០២២)។ លោក Senge គ្រូបង្រៀនត្រូវបានគេកំណត់ថាជាអ្នកជំនាញដែលមានសមត្ថភាពចែកចាយចំណេះដឹង ដែលនឹងជួយអ្នកសិក្សាក្នុងការកសាង កំណត់អត្តសញ្ញាណ និងទទួលបានជំនាញដែលនឹងត្រូវបានប្រើដើម្បីប្រឈមមុខនឹងបញ្ហាក្នុងជីវិត។ គ្រូផ្តល់ចំណេះដឹង ជំនាញ និងគុណតម្លៃដល់សិស្សដែលលើកកម្ពស់ការអភិវឌ្ឍន៍។ ដូច្នេះ គ្រូគឺជាបុគ្គលដែលផ្តល់ការអប់រំដល់សិស្ស។ លើសពីនេះទៅទៀត គ្រូបង្រៀនជាអ្នកបង្ហាត់បង្រៀនសិស្ស ដោយផ្ទាល់ហើយជោគវាសនារបស់ពួកគេសង្ឃឹមលើគ្រូបង្រៀនទាំងស្រុង (វិទ្យាស្ថានជាតិអប់រំ(២០១៦) ការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ទំព័រទី៣៥)។

ឆ្លងតាមការបកស្រាយទ្រឹស្តីខាងលើ យើងអាចនិយាយបានថា គ្រូបង្រៀនជាអ្នកដែលមានទេពកោសល្យប៉ិនប្រសព្វពោលគឺ ចេះប្រើប្រាស់ចំណេះដឹងដើម្បីអប់រំសិស្ស ចេះប្រើប្រាស់វិធីសាស្ត្របង្រៀនសិស្ស ចេះបង្កើនគុណភាពរៀននិងបង្រៀន និងចេះបង្កើតបរិយាកាសសិក្សាល្អសម្រាប់ការសិក្សារបស់សិស្ស។

### ២.១.៣ វិជ្ជាជីវៈគ្រូបង្រៀន

ការកំណត់ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនពីប្រទេសមួយទៅប្រទេសមួយ ផ្អែកលើកត្តាច្រើនយ៉ាងដូចជាកត្តាបច្ចេកវិទ្យា សេដ្ឋកិច្ច សង្គម និងវប្បធម៌។ ដោយឡែកស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀននៅកម្ពុជាយើងបានកំណត់ជាបួនសមាសភាគគឺ ចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ។ សមាសភាគនីមួយៗមានអនុសមាសភាគជាច្រើន និងនៅក្នុងសមាសភាគនីមួយៗមានបញ្ជាក់ពីសមាសភាពលម្អិតតូចៗសម្រាប់ផ្ទៀងផ្ទាត់សមត្ថភាពស្តែងឡើង។

ទោះបីស្តង់ដាបានលើកឡើងពីសមត្ថភាពសំខាន់ៗជាច្រើនតែយើងនឹងជ្រើសរើសយកតែសមត្ថភាពមួយចំនួនដែលយើងចាត់ទុកថា ជាសមត្ថភាពអប្បបរមាប៉ុណ្ណោះ ឯសមត្ថភាពផ្សេងទៀតនឹងត្រូវលើកយកមកបង្ហាញនាពេលអនាគត។ ជាមួយគ្នានេះ យើងក៏មានជំនឿជាក់ផងដែរថា គ្រូបង្រៀនទាំងអស់សមត្ថភាពដល់ស្តង់ដាអប្បបរមាហើយ។

ឧទាហរណ៍៖ ការបង្ហាញពីការប្តេជ្ញាចិត្ត និងការចូលរួមចំណែកក្នុងវិជ្ជាជីវៈគ្រូបង្រៀន។ ឯស្តង់ដាផ្សេងទៀត យើងដឹងថាគ្រូបង្រៀនភាគច្រើនកំពុងធ្វើ ផ្តល់បរិស្ថានសិក្សាដែលមានសុវត្ថិភាពនិង

ធ្វើឱ្យសិស្សរៀនអស់ពីសមត្ថភាព។ ឯស្តង់ដាខ្លះទៀតមានតែគ្រូមួយចំនួនតូចទេដែលអាចធ្វើបានប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងធនធានក្នុងបណ្ណាល័យដើម្បីធ្វើឱ្យការបង្រៀនមានប្រសិទ្ធភាព (ក្រសួងអប់រំ យុវជន និងកីឡា (២០១០) ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ទំព័រទី១៣)។

## ២.២ ចំណេះដឹង និងការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀន

គ្រូបង្រៀនត្រូវមានចំណេះដឹងវិជ្ជាជីវៈសម្បូរបែប។ គ្រូបង្រៀនត្រូវយល់ដឹងពីបរិស្ថានអប់រំក្នុងថ្នាក់រៀននិងក្នុងសហគមន៍ ជាពិសេសយល់ពីរបៀបរៀនរបស់សិស្សភាពខុសគ្នារវាងទេព្យកោសល្យល្បឿន និងរបៀបសិក្សាដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស។ ក្នុងន័យនេះ គ្រូបង្រៀនត្រូវសិក្សានិងពណ៌នាបាននូវស្ថានភាពរបស់សិស្សដូចជា៖ (១). ពណ៌នាបានពីតម្រូវការសិក្សារបស់សិស្ស (២). ពណ៌នាបានពីសមត្ថភាពសិក្សារបស់សិស្ស (៣). ពណ៌នាបានពីប្រវត្តិសិក្សារបស់សិស្ស និង (៤). ពណ៌នាបានពីឥរិយាបថសិក្សារបស់សិស្ស។ គ្រូបង្រៀនត្រូវយល់ដឹងពណ៌នាពីប្រភេទគ្រួសារ និងកត្តាផ្សេងៗដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្សដូចជា៖ (១). កត្តាយេនឌ័រ (២). កត្តាសង្គមនិងសេដ្ឋកិច្ច (៣). ក្រុមជនជាតិនិងពិការភាព និង(៤). របៀបដោះស្រាយបញ្ហាដែលកើតចេញពីកត្តាទាំងនោះ (ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ទំព័រទី៨)។

មួយវិញទៀត គ្រូបង្រៀនត្រូវយល់ដឹងពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះដឹងទូទៅដូចតទៅ៖ (១). ពណ៌នាបានពីគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះដឹងទូទៅ (២). ពណ៌នាបានពីវិធីដែលធ្វើឱ្យសម្រេចគោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះដឹងទូទៅ។ គ្រូបង្រៀនត្រូវតែយល់ដឹងពីទ្រឹស្តីនៃការសរសេរ កិច្ចតែងការបង្រៀនរួមមាន៖ (១). ពណ៌នាបានពីវត្ថុបំណងនិងធាតុរបស់វាបានត្រឹមត្រូវ (២). ពណ៌នាបានពីចំណុចសំខាន់ៗនៃគោលវិធីសិស្សមជ្ឈមណ្ឌល (៣). ពណ៌នាបានពីយុទ្ធវិធីវាយតម្លៃលទ្ធផលសិក្សារបស់សិស្សបានសមស្រប (៤). ពណ៌នាបានពីសម្ភារបង្រៀននិងរៀនបានសមស្របសម្រាប់ប្រើប្រាស់ក្នុងការបង្រៀនមេរៀន។ គ្រូបង្រៀនត្រូវតែយល់ដឹងពីខ្លឹមសារកម្មវិធីសិក្សា ហើយមានសមត្ថភាពពន្យល់និងបង្រៀនខ្លឹមសារមុខវិជ្ជាដែលមានក្នុងវិធីសិក្សាបានល្អ។ គ្រូបង្រៀនត្រូវយល់ដឹងពី

របៀបគូសបញ្ជាក់ពីខ្លឹមសារសំខាន់ៗ នៃកម្មវិធីសិក្សាដែលត្រូវបង្រៀនច្បាស់លាស់និងបង្រៀនដើម្បីបង្ហាញពីការយល់ខ្លឹមសារច្បាស់លាស់។ លើសពីនេះគ្រូបង្រៀនត្រូវតែយល់ដឹងពីរបៀបបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយផ្សេងទៀត ក្នុងន័យឱ្យសិស្សទទួលបានបំណិនជាច្រើននិងមានចិត្តកាន់តែចង់រៀន។ គ្រូបង្រៀនអាចពណ៌នាបានពីវិធីបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយផ្សេងទៀតដែលអាចជួយឱ្យសិស្សរៀនកាន់តែប្រសើរឡើងនិងចូលចិត្តរៀន (ក្រសួងអប់រំ យុវជន និងកីឡា(២០១៦) ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ទំព័រទី៨)។

នៅក្នុងការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀនត្រូវរៀបចំកិច្ចតែងការបង្រៀនឱ្យបានច្បាស់លាស់ប្រកបដោយប្រសិទ្ធភាពស្របតាមកម្មវិធីសិក្សាដោយផ្អែកលើ សៀវភៅសិស្ស សៀវភៅគ្រូ និងសម្ភារសិក្សាផ្សេងៗទៀតដែលអាចរកបាន។ ដើម្បីគាំទ្រដល់កិច្ចតែងការបង្រៀន គ្រូបង្រៀនត្រូវរៀបចំសម្ភារបង្រៀន និងរៀនដើម្បីរិះរកមធ្យោបាយសម្រេចការសិក្សារបស់សិស្សប្រកបដោយប្រសិទ្ធភាព។ គ្រូបង្រៀនត្រូវចេះប្រើប្រាស់វិធីបង្រៀនឱ្យសម្បូរបែប ដើម្បីសម្រួលដល់ការសិក្សារបស់សិស្សដោយបង្កឱកាសឱ្យសិស្សចូលរួមគិតបានល្អិតល្អន់និងដោយច្នៃប្រឌិត និងសម្រេចបានវត្ថុបំណងមេរៀន។ម្យ៉ាងទៀតគ្រូបង្រៀនគួរមានសមត្ថភាពផ្តល់ជាមធ្យោបាយឱ្យស្របទៅតាមរបៀបសិក្សា និងតម្រូវការផ្សេងៗគ្នារបស់សិស្សតាមរយៈការអនុវត្តវិធីបង្រៀនសមស្របសម្បូរបែបដោយបង្កឱកាសឱ្យសិស្សចូលរួមគិតបានល្អិតល្អន់និងដោយច្នៃប្រឌិត។ លើសពីនេះទៅទៀត គ្រូបង្រៀនត្រូវចេះប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងធនធានក្នុងបណ្ណាល័យបើមានលទ្ធភាពដើម្បីធ្វើឱ្យការបង្រៀន និងរៀនកាន់មានប្រសិទ្ធភាព (ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ទំព័រទី១៣)។

ដោយឡែក គ្រូបង្រៀនត្រូវយល់ដឹងពីការប្រើប្រាស់វិធីសមស្របសម្បូរបែបសម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្សមួយចំនួនរួមមាន៖ (១). កសាងសំណួរតេស្តដោយមានទម្រង់ និងរយៈពេលសមស្របសម្រាប់សិស្សឆ្លើយ(២). ជ្រើសរើសអាយតឹមតេស(Item Test) ពីសៀវភៅផ្សេងៗដែលមានទម្រង់សំណួរនិងរយៈពេលសមស្របសម្រាប់សិស្សឆ្លើយ (៣). បង្ហាញប្រាប់ពីអត្រាកំណែតេសនិងការកែចម្លើយរបស់

សិស្សបានត្រឹមត្រូវ និង(៤). កំណត់បានយ៉ាងច្បាស់លាស់ពីលទ្ធផលតែសដើម្បីបង្ហាញពីប្រសិទ្ធភាពនៃការសិក្សារបស់សិស្ស (ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ទំព័រទី១២)។

គ្រូបង្រៀនត្រូវតាមដានការចូលរួម និងថែរក្សាកំណត់ត្រានៃភាពរីកចម្រើនរបស់សិស្សដូចជា៖ (១). តាមដានការចូលរួមរបស់សិស្សតាមរយៈការសង្កេត និងធ្វើកំណត់ត្រានិង(២).ថែរក្សាកំណត់ត្រាស្តីពីការចូលរួមរបស់សិស្សក្នុងសកម្មភាពសិក្សា។ គ្រូបង្រៀនត្រូវផ្តល់ព័ត៌មានត្រឡប់ទៅសិស្ស មាតាបិតា ឬ អាណាព្យាបាលសិស្សអំពីការអភិវឌ្ឍចំណេះដឹងបំណិន និងឥរិយាបថរបស់សិស្សដូចជា៖ (១). ផ្តល់ព័ត៌មានត្រឡប់ទៅសិស្សតាមរយៈការនិយាយដោយផ្ទាល់ និងដាក់មូលវិចារសមស្របជាលាយលក្ខណ៍អក្សរនៅលើសន្លឹកកិច្ចការរបស់សិស្ស ជាពិសេសលើសៀវភៅទំនាក់ទំនង (២). ផ្តល់ព័ត៌មានត្រឡប់ទៅមាតាបិតាឬអាណាព្យាបាលសិស្សតាមរយៈរបាយការណ៍ប្រចាំខែ និងទៅជួបផ្ទាល់បើចាំបាច់ (ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ទំព័រទី១២)។

ទន្ទឹមគ្នានេះ គ្រូបង្រៀនត្រូវផ្តល់បរិស្ថានសិក្សាដែលមានសុវត្ថិភាពនិងធ្វើឱ្យសិស្សទាំងអស់ខិតខំរៀនអស់ពីលទ្ធភាពដូចជា៖(១). បង្ហាញឱ្យឃើញពីការគ្រប់គ្រងថ្នាក់រៀនមានប្រសិទ្ធភាព(២).ជួយសិស្សឱ្យមានអន្តរកម្មវិជ្ជមានជាមួយសិស្សដទៃទៀត និង(៣).ផ្តល់បរិស្ថានសិក្សាដែលធ្វើឱ្យសិស្សពង្រីកការសិក្សាបានច្រើន។ គ្រូបង្រៀនត្រូវជួយសិស្សឱ្យបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួនមួយចំនួនរួមមាន៖ (១). បង្ហាញពីវិធីដែលអាចជួយសិស្សឱ្យមានការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួនកាន់តែខ្លាំង(២).បង្ហាញកិច្ចការសិស្សជាឧទាហរណ៍ដែលចង្អុលបង្ហាញការរៀនដោយខ្លួនឯង និង(៣). កិច្ចការសិស្សគម្រោងតូចៗរបាយការណ៍តាមក្រុម។ គ្រូបង្រៀនត្រូវចូលរួមអភិវឌ្ឍន៍សាលារៀនដើម្បីទ្រទ្រង់ការសិក្សានិងសុខុមានភាពរបស់សិស្សព្រមទាំងសហសេវិក-មិត្តរួមអាជីពដូចជា៖ (១). ពណ៌នាបានពីសកម្មភាពអភិវឌ្ឍសាលារៀនដែលគាត់បានចូលរួម និង (២). លើកជាសំណូមពរពីសកម្មភាពអភិវឌ្ឍន៍សាលារៀន។ ស្របជាមួយគ្នានេះគ្រូបង្រៀនត្រូវប្រើវិធីបង្រៀនផ្សេងៗដើម្បីជួយសម្រួលការសិក្សារបស់សិស្ស និងសម្រេចឱ្យបានតាមស្តង់ដាកម្មវិធីសិក្សារបស់ក្រសួងមួយចំនួនដូចជា៖(១). បង្ហាញពីវិធីផ្សេងៗដូចជាអនុមានរួម អនុមានញែក ការងារក្រុមពន្យល់បង្ហាញពីដំណោះស្រាយបញ្ហា (២). ពណ៌នាបានពីវិធីបង្រៀន

ដែលមានប្រសិទ្ធភាពចំពោះមេរៀននីមួយៗដែលបានប្រើ ពិសេសអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបានត្រឹមត្រូវ និង(៣). ពន្យល់បានពីមូលហេតុដែលប្រើវិធីបង្រៀនទាំងនោះ។ គ្រូបង្រៀនត្រូវផ្តល់មធ្យោបាយឱ្យស្របទៅតាមរបៀបសិក្សា និងតម្រូវការផ្សេងៗគ្នារបស់សិស្សតាមរយៈការអនុវត្តវិធីបង្រៀនសមស្រប និងសម្បូរបែបដូចជា៖ (១). បង្ហាញពីវិធីបង្រៀនផ្សេងៗដែលផ្តល់ជាមធ្យោបាយឱ្យត្រូវទៅតាមរបៀបសិក្សារបស់សិស្សផ្សេងៗគ្នា(ឧ.ពូកែខាងភាសា គណិត ចក្ខុ ចលនារាងកាយតន្ត្រីទាក់ទងរវាងបុគ្គលនិងបុគ្គល) និង(៣). ពន្យល់បានពីវិធីបង្រៀនដែលផ្តល់ជាមធ្យោបាយឱ្យត្រូវទៅតាមរបៀបសិក្សាខុសៗគ្នារបស់សិស្ស។ គ្រូបង្រៀនត្រូវរៀបចំ និងផ្តឱ្យសិស្សនូវឱកាសសិក្សាពីដំណោះស្រាយបញ្ហាដើម្បីចូលរួមគិតឱ្យបានល្អិតល្អន់និងដោយច្នៃប្រឌិតរួមមាន៖ (១). ជួយសិស្សឱ្យប្រើការគិតល្អិតល្អន់ដើម្បីវិភាគចំណោទបញ្ហា និង(២). ពណ៌នាបានពីរបៀបដែលគាត់ប្រើការគិតដោយច្នៃប្រឌិតដើម្បីដោះស្រាយបញ្ហា (ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ទំព័រទី១៥)។

ចុងក្រោយនេះ គ្រូបង្រៀនត្រូវប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍និងធនធានក្នុងបណ្ណាល័យ ដើម្បីធ្វើឱ្យការបង្រៀននិងរៀនកាន់តែមានប្រសិទ្ធភាពដូចជា៖(១). ពណ៌នាបានពីរបៀបប្រើប្រាស់ បច្ចេកវិទ្យាពត៌មាននិងសារគមនាគមន៍ដើម្បីជួយឱ្យសិស្សមានចិត្តចង់រៀន (២). ពណ៌នាបានពីរបៀបប្រើប្រាស់ចំណេះដឹងនិងបំណិនបច្ចេកវិទ្យាពត៌មាន និងសារគមនាគមន៍ដើម្បីឱ្យសិស្សរៀនកាន់តែមានប្រសិទ្ធភាព(ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ទំព័រទី១៦)។

## ២.៣ ការសិក្សាវិជ្ជាជីវៈគ្រូបង្រៀន

យើងបានដឹងហើយថា គ្រូបង្រៀនគឺជាអ្នកលើកទឹកចិត្ត និងជាអ្នកធានាឱ្យសិស្សទទួលបានជោគជ័យក្នុងការសិក្សា។ ដូចនេះ គាត់ត្រូវតែស្វ័យសិក្សា វាយតម្លៃការបង្រៀន ដើម្បីអភិវឌ្ឍខ្លួនឯង និងប្រើប្រាស់ផែនការសម្រាប់ដឹកនាំស្វ័យសិក្សាវិជ្ជាជីវៈជាប្រចាំស្របតាមជីវភាពរស់នៅជាក់ស្តែង។ គ្រូបង្រៀនត្រូវអភិវឌ្ឍផ្នែកបច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងបំណិនផ្សេងៗសម្រាប់ការអនុវត្តក្នុងការបង្រៀន ហើយធ្វើឱ្យប្រសើរឡើងបំណិនទំនាក់ទំនងជាមួយ សិស្ស មាតាបិតា មិត្តរួមការងារ ឬអាជីព និងជាមួយអ្នកផ្សេងទៀតនៅក្នុងសហគមន៍។ គ្រូបង្រៀនត្រូវលើកកម្ពស់កម្រិតសមត្ថភាពវិជ្ជាជីវៈរបស់

ខ្លួនតាមរយៈការអាន និងសិក្សាស្រាវជ្រាវប្រភពឯកសារផ្សេងៗ ដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងកែលំអការបង្រៀន និងរៀន ហើយត្រូវមានទំនាក់ទំនងល្អជាមួយគ្រូដទៃទៀតក្នុងការសិក្សាវិជ្ជាជីវៈ (ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ទំព័រទី១៦-១៨)។

ផ្តើមចេញពីនេះ គ្រូបង្រៀនត្រូវចេះវាយតម្លៃការបង្រៀន ការអភិវឌ្ឍខ្លួននិងការប្រើប្រាស់ផែនការសម្រាប់ដឹកនាំស្វ័យសិក្សាវិជ្ជាជីវៈបានទៀងទាត់ រួមមាន៖ (១). កំណត់បានពីចំណុចខ្លាំង ចំណុចដែលត្រូវកែលម្អនិងតម្រូវការក្នុងមុខវិជ្ជាជីវៈផ្ទាល់ខ្លួន (២). រៀបចំផែនការអភិវឌ្ឍវិជ្ជាជីវៈផ្ទាល់ខ្លួនប្រកបដោយប្រសិទ្ធភាព និង(៣). ស្វែងយល់ពីការប្រើប្រាស់សៀវភៅកំណត់ត្រាប្រចាំថ្ងៃដើម្បីឆ្លុះបញ្ចាំងការងាររបស់ខ្លួន។ គ្រូបង្រៀនត្រូវអភិវឌ្ឍចំណេះដឹងបច្ចេកវិទ្យាពត៌មានសារគមនាគមន៍ និងបំណិនសម្រាប់អនុវត្តក្នុងការបង្រៀននិងរៀនមួយចំនួនដូចជា៖ (១). បង្កើនបំណិនដែលទាក់ទងនឹងវិជ្ជាជីវៈរបស់ខ្លួនដោយបង្ហាញវិញ្ញាបនបត្រជាភស្តុតាង(២). ពណ៌នាបានពីរបៀបប្រើប្រាស់បច្ចេកវិទ្យាពត៌មានសារគមនាគមន៍សម្រាប់ការស្រាវជ្រាវ និងរៀនដោយខ្លួនឯង (៣). មានឆន្ទៈស្វ័យសិក្សាស្រាវជ្រាវបំពេញបន្ថែមទាំងចំណេះដឹងមូលដ្ឋានទាំងចំណេះបច្ចេកទេសបង្រៀនថ្មីៗតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាពត៌មាន និងសារគមនាគមន៍ (ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ទំព័រទី១៦-១៨)។

លើសពីនេះ គ្រូបង្រៀនត្រូវធ្វើឱ្យប្រសើរឡើងនូវបំណិនទំនាក់ទំនង ជាមួយសិស្ស មាតាបិតា មិត្តរួមអាជីពនិងសហគមន៍ដូចជា៖ (១). បង្ហាញពីបំណិនទំនាក់ទំនងជាមួយសិស្ស (២). បង្ហាញពីបំណិនទំនាក់ទំនងជាមួយសហការី (៣). បង្ហាញពីបំណិនទំនាក់ទំនងជាមួយមាតាបិតានិងសហគមន៍។ គ្រូបង្រៀនត្រូវអានអត្ថបទវិជ្ជាជីវៈគ្រូបង្រៀន និងស្រាវជ្រាវដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងន័យធ្វើឱ្យការបង្រៀនកាន់តែប្រសើរដូជា៖(១).ពណ៌នាបានពីអត្ថបទដែលគាត់បានអាន និងស្រាវជ្រាវ ហើយយកបទពិសោធក្នុងអត្ថបទនោះមកជួយកែលំអការបង្រៀន (២). ធ្វើថ្នាក់និទស្សន៍ដើម្បីបង្ហាញបទពិសោធដែលទទួលបានពីការអាន និងស្រាវជ្រាវឯកសារផ្សេងៗដល់មិត្តរួមអាជីពដើម្បីបង្កើនសមត្ថភាព។ គ្រូបង្រៀនត្រូវធ្វើអន្តរកម្មជាមួយគ្រូដទៃទៀតក្នុងសកម្មភាពសិក្សាវិជ្ជាជីវៈផ្សេងៗរួមមាន៖ (១). ធ្វើបញ្ជីឈ្មោះសិក្ខាសិលាឬវគ្គបំប៉នផ្សេងៗ ដែលបានចូលរួម (២). ពន្យល់បានពីខ្លឹមសារសិក្ខាសិលាឬវគ្គបំប៉ន

ដែលបានចូលរួមហើយបានផ្តល់បទពិសោធល្អៗដល់ការបង្រៀននិងរៀន(ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ទំព័រទី១៦-១៨)។

## ២.៤ សីលធម៌វិជ្ជាជីវៈគ្រូបង្រៀន

សីលធម៌វិជ្ជាជីវៈ គឺពាក់ព័ន្ធទៅនឹងគ្រប់ទិដ្ឋភាពទាំងអស់ក្នុងវិជ្ជាជីវៈគ្រូបង្រៀនដែលជារួមមានការប្តេជ្ញាចិត្តបង្រៀនសិស្សប្រើប្រាស់មនសិការវិជ្ជាជីវៈប្រកបដោយគតិបណ្ឌិត និងមានចំណេះដឹងគ្រប់គ្រាន់តាមក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងច្បាប់ស្តីពីការអប់រំ។ គ្រូបង្រៀនត្រូវគោរពពេលវេលាតាមភារកិច្ចមានវត្ត មានជាប្រចាំនៅក្នុងសាលារៀន មានការស្លៀកពាក់សមរម្យ និងមានឥរិយាបថថ្លៃថ្នូរ។ គាត់គួរតែចូលរួមក្នុងគ្រប់សកម្មភាពទាំងក្នុង និងក្រៅម៉ោងទាំងអស់របស់សាលារៀនឱ្យបានសមស្របតាមករណីដែលអាចធ្វើបាន។ គ្រូបង្រៀនមានប្រសិទ្ធភាព គឺមិនរើសអើងសិស្ស ទោះក្នុងកាលៈទេសៈណាក៏ដោយដូចជាបញ្ហាយេនឌ័រ ជនជាតិភាគតិច ពិការភាព ក្រីក្រ និងត្រូវចេះថែទាំសិស្ស ផ្តល់លទ្ធភាពឱ្យសិស្សប្រើប្រាស់ធនធានឱ្យអស់ពីលទ្ធភាព ហើយយកចិត្តទុកដាក់ដល់សិស្សឱ្យបានស្មើៗគ្នារួចបង្ហាញពីភាពយុត្តិធម៌ក្នុងការត្រួតពិនិត្យលទ្ធផលសិក្សា។ នៅពេលទាក់ទងជាមួយសិស្ស គ្រូបង្រៀនត្រូវមានការគោរពសិស្សដោយមិននិយាយមើលងាយឬដាក់ទណ្ឌកម្មពួកគេតាមរបៀបហឹង្សាឡើយ។ គ្រូបង្រៀនត្រូវប្រកាន់ចរិយាសម្បត្តិមានសុជីវធម៌ និងអាកប្បកិរិយាថ្លៃថ្នូរសម្រាប់ធ្វើការសហការជាមួយសហការី និងមាតាបិតាសិស្សដើម្បីផលប្រយោជន៍សិស្ស ផ្តល់ជាគំរូដល់សិស្សក្នុងការរស់នៅ និងរៀនសូត្របានល្អ ពិសេសចេះលើកកម្ពស់ស្មារតីសិស្សឱ្យរឹងប៉ឹង និងវិជ្ជមានហើយបង្កើតស្មារតីលះបង់ និងការរួមចំណែកចំពោះ សហគមន៍ទាំងមូល (ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ទំព័រទី១៩)។

ផ្តើមចេញពីនេះ គ្រូបង្រៀនត្រូវបង្ហាញពីការយកចិត្តទុកដាក់ និងថែរក្សាសិស្សហើយជានិច្ចជាកាលធ្វើការដើម្បីប្រយោជន៍សិស្សនិងសង្គមរួមមាន៖ (១). និយាយទៅកាន់សិស្ស សហការី និងអ្នកឯទៀតនៅក្នុងសហគមន៍ដោយមានការគោរពនិងលើកទឹកចិត្ត (២). បង្ហាញពីការគោរពសិទ្ធិកុមារ មិនត្រូវនិយាយមើលងាយ ឬដាក់ពិន័យសិស្សតាមរបៀបអំពើហិង្សា និង (៣). ធ្វើការជាមួយសហការីនិងសមាជិកសហគមន៍ឯទៀតដើម្បីប្រយោជន៍សិស្ស។ គ្រូបង្រៀនត្រូវបង្ហាញពីការប្តេជ្ញាចិត្ត និងចូលរួមចំណែកក្នុងវិជ្ជាជីវៈគ្រូបង្រៀនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចជា៖ (១). ទៅថ្នាក់រៀននិងចូលរួមព្រឹត្តិការណ៍

ផ្សេងៗបានទៀងទាត់និងទាន់ពេលវេលា (២). បង្ហាញពីអាកប្បកិរិយារាក់ទាក់និងសប្បុរសធម៌ (៣). បង្ហាញពិការគោរពសិស្ស សហការី និងអ្នកឯទៀតក្នុងសហគមន៍ (៣). បង្ហាញពីអារម្មណ៍ជក់ចិត្តនិងគំនិតផ្តួចផ្តើមលើគ្រប់ទិដ្ឋភាពនៃសកម្មភាពវិជ្ជាជីវៈ និង(៤). បង្ហាញពីចំណេះដឹងលើក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀននិងច្បាប់ស្តីពីការអប់រំ (ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ទំព័រទី២០)។

លើសពីនេះទៅទៀត គ្រូបង្រៀនត្រូវបង្ហាញអាកប្បកិរិយាវិជ្ជមានជាគំរូប្រកបដោយសីលធម៌និងមានទំនាក់ទំនងដោយសុខដុមជាមួយសិស្សនិងសហគមន៍ដូចជាៈ (១). ស្លៀកពាក់សមរម្យ (២). បង្ហាពីអារម្មណ៍វិជ្ជមានចំពោះសិស្សនិងអ្នកឯទៀត (៣). បង្ហាញពីសមត្ថភាពដើម្បីរក្សាទំនាក់ទំនងប្រកបដោយសុខដុម និង(៤). ផ្តល់តម្លៃសីលធម៌ទៅមាតាបិតាសិស្សនិងអ្នកឯទៀត។ គ្រូបង្រៀនត្រូវប្រើប្រាស់ភាពយុត្តិធម៌និងតម្លាភាពក្នុងការប្រព្រឹត្តជាមួយសិស្ស និងសហសេវិកនិងសមាជិកផ្សេងៗរបស់សហគមន៍ដូចជាៈ(១). បង្ហាញ់ពីភាពស្មោះត្រង់ក្នុងមុខវិជ្ជាជីវៈដោយសំដែងនូវសុភាវធម៌ និងភាពមិនលំអៀង (២). ផ្តល់ឱកាសដល់សិស្សគ្រប់រូបមានលទ្ធភាពទទួលយកបាននូវពេលវេលា និងធនធានស្មើៗគ្នាដោយមិនគិតពីភេទ ជនជាតិដើមភាគតិច ឬអ្នកក្រីក្រនិងពិការភាព និង(៣). វាយតម្លៃលទ្ធផលសិក្សាប្រកបដោយយុត្តិធម៌។

សរុបចេក្តីមក សីលធម៌វិជ្ជាជីវៈគ្រូបង្រៀន សំដៅលើសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនដែលត្រូវចូលរួមបំពេញមុខងារនៅក្នុងសង្គម។ ហេតុដូចនេះ គ្រូបង្រៀនដែលប្រកបមុខរបរត្រូវតែយល់ដឹងពីសីលធម៌វិជ្ជាជីវៈដែលទាក់ទងនឹងមុខរបរនោះ។ មានន័យថាសីលធម៌វិជ្ជាជីវៈជាសីលធម៌ដែលគ្រូបង្រៀនត្រូវសិក្សាស្វែងយល់ និងប្រតិបត្តិឱ្យបានត្រឹមត្រូវព្រោះមនុស្សដែលមានសីលធម៌ជាមនុស្សដែលមានកិត្តិយសមានសេចក្តីថ្លៃថ្នូរទទួលបានការគោរពពីអ្នកដទៃ (ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ទំព័រទី២០-២១)។

# ជំពូក ៣
# វិធីសាស្ត្រស្រាវជ្រាវ

ជំពូកនេះ បានធ្វើការពន្យល់បកស្រាយអំពីវិធីសាស្ត្រស្រាវជ្រាវរួមមាន ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ ការជ្រើសរើសសំណាក ប្រភពទិន្នន័យ ការប្រមូលទិន្នន័យ ការវិភាគទិន្នន័យនិងក្រមសីលធម៌នៃការស្រាវជ្រាវ។

## ៣.១ ការជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវតាមគុណវិស័យដោយប្រើប្រាស់កម្រងសំណួរ២ប្រភេទគឺ កម្រងសំណួរសម្ភាស និងកម្រងសំណួរបំពេញ។ កម្រងសំណាយរសម្ភាសឆ្លុះបញ្ចាំងទៅសំណួរស្រាវជ្រាវទី១នៃប្រធានបទ និងកម្រងសំណួរបំពេញឆ្លុះបញ្ចាំងទៅសំណួរស្រាវជ្រាវទី២ និងទី៣ នៃប្រធានបទដែលបានលើកមកសិក្សាស្រាវជ្រាវ។ ការវិភាគទិន្នន័យតាមគុណវិស័យ បានប្រើប្រាស់វិធីសាស្ត្រវិភាគខ្លឹមសារ(Content Analysis Method) ដើម្បីពន្យល់បកស្រាយទិន្នន័យដែលទទួលបានពីការសម្ភាស និងការវិភាគទិន្នន័យតាមបរិមាណវិស័យដោយប្រើប្រាស់កម្មវិធី Excel សម្រាប់បញ្ចូលទិន្នន័យ និងគណនាភាគរយ។

## ៣.២ ការជ្រើសរើសសំណាក

ការសិក្សានេះ បានប្រើប្រាស់នូវចំនួនសំណាកចំនួន១១៨សំណាក់ក្នុងនោះមានគណៈគ្រប់គ្រងនិងគ្រូបង្រៀននៅកម្រិតសិក្សាបឋមភូមិចំនួន១១៨នាក់ដែលកំពុងបង្រៀនក្នុងឆ្នាំសិក្សា២០២២-២០២៣។ ការប្រមូលទិន្នន័យត្រូវបានធ្វើឡើងនៅអនុវិទ្យាល័យនិងវិទ្យាល័យគោលដៅចំនួន១០ក្នុងខេត្តតាកែវដើម្បីធ្វើការសម្ភាស និងបំពេញកម្រងសំណួរ។ សាលាគោលដៅទាំងនោះរួមមាន៖ អនុវិទ្យាល័យគោកពោធិ៍ វិទ្យាល័យសុខអានដូងខ្ពស់ អនុវិទ្យាល័យស្នោង អនុវិទ្យាល័យអង្គស្លឹ អនុវិទ្យាអង្គមេត្រី អនុវិទ្យាល័យបារាយណ៍ អនុវិទ្យាល័យអង្គក្តី វិទ្យាល័យសុខអានក្តីទន្ទឹម វិទ្យាល័យហ៊ុន សែន ស្លាគូ និងវិទ្យាល័យសុខអានលាយបូសាលា ដែលស្ថិតនៅក្នុងក្រុង-ស្រុក ចំនួន៥ (ក្រុងដូនកែវ ស្រុកបូរីជលសារ សំរោងទ្រាំង និងស្រុកត្រាំកក់ ) កម្រងសំណួរត្រូវបានធ្វើឡើងសម្រាប់អ្នកចូលរួមចំនួន១១៨នាក់។ អ្នកចូលរួម

នៃអ្នកឆ្លើយកម្រងសំណួរគ្រូបង្រៀននៃអនុវិទ្យាល័យ និងវិទ្យាល័យទាំង១០ក្នុងខេត្តតាកែវ។ សម្ភាសន៍ផ្ទាល់បានចូលរួមចំនួន១៥នាក់(គណៈគ្រប់គ្រងសាលាចំនួន០៥នាក់ និងគ្រូបង្រៀនចំនួន១០ នាក់)។ ការជ្រើសរើសវិភាគសំណាក ត្រូវបានជ្រើសរើសតាមគោលការណ៍ និងធ្វើការកំណត់វិធីសាស្ត្រជ្រើសរើសវិភាគសំណាកដោយការប្រើវិធីសាស្ត្រជ្រើសរើសសំណាកតាមបែបចៃដន្យ (Kumar (2011) វិធីសាស្ត្រជ្រើសរើសសំណាក ទំព័រទី៤០)។

*តារាង ៣.១៖ ចំនួនភាគសំណាក*

| ល.រ | ឈ្មោះសាលារៀន | គណៈគ្រប់គ្រង | គ្រូបង្រៀន |
|---|---|---|---|
| ១. | អនុវិទ្យាល័យគោកពោធិ៍ | ១ | ១០ |
| ២ | វិទ្យាល័យសុខអានដូងខ្ពស់ | ១ | ១៣ |
| ៣ | អនុវិទ្យាល័យស្មោង | ១ | ១០ |
| ៤ | អនុវិទ្យាល័យអង្គស្លី | ១ | ១០ |
| ៥ | អនុវិទ្យាអង្គមេត្រី | ១ | ១០ |
| | | គ្រូបង្រៀន | |
| ៦ | អនុវិទ្យាល័យបារាយណ៍ | ២ | ១០ |
| ៧ | អនុវិទ្យាល័យអង្គក្តី | ២ | ១០ |
| ៨ | វិទ្យាល័យសុខអានក្តីទន្ទឹម | ២ | ១០ |
| ៩ | វិទ្យាល័យហ៊ុន សែនស្លាគូ | ២ | ១០ |
| ១០ | វិទ្យាល័យសុខអានលាយបូ | ២ | ១០ |
| សរុបចំនួនភាគសំណាក ១១៨នាក់ | | **១៥** | **១០៣** |

## ៣.៣ ប្រភពទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់សម្ភាសផ្ទាល់ និងកម្រងសំណួរ។ សម្ភាសផ្ទាល់ត្រូវបាន ធ្វើឡើងសម្រាប់ការប្រមូលទិន្នន័យ ដើម្បីសិក្សាពីទស្សនរបស់គ្រូបង្រៀនចំពោះស្ថានភាពនៃការ

ប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅកម្រិតអនុវិទ្យាល័យ។ កម្រងសំណួរត្រូវបានប្រើប្រាស់សម្រាប់ការសិក្សាឈ្វេងយល់ និងសិក្សាបញ្ហាប្រឈមនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅកម្រិតអនុវិទ្យាល័យក្នុងខេត្តតាកែវ ។

## ៣.៤ វិធីសាស្ត្រប្រមូលទិន្នន័យ

### ៣.៤.១ សម្ភាសផ្ទាល់

អ្នកសិក្សាស្រាវជ្រាវ បានអនុវត្តសម្ភាសន៍ផ្ទាល់ក្រោយពេលកម្រងសំណួរត្រូវបានបញ្ចប់មួយសប្តាហ៍រួចមក។ អ្នកចូលរួម១៥ នាក់(គណៈគ្រប់គ្រងចំនួន០៥ នាក់ និងគ្រូបង្រៀនចំនួន១០ នាក់) ក្នុងចំណោម១១៨នាក់ត្រូវបានស្នើសុំ និងធ្វើការសម្ភាស។ មុនការចាប់ផ្តើមធ្វើការសម្ភាស អ្នកសិក្សាស្រាវជ្រាវបានបង្ហាញពីគោលបំណងនៃការស្រាវជ្រាវ និងចែកសំណួរដែលត្រូវសម្ភាសទៅអ្នកចូលរួមមើលមុន។ បន្ទាប់ពីការចែកសំណួរសម្ភាសជូនដល់អ្នកចូលរួមរួចមក អ្នកសិក្សាស្រាវជ្រាវចាប់ផ្តើមធ្វើសម្ភាស និងថតសម្លេងនៃការសម្ភាសនោះទុកជាទិន្នន័យនៃការស្រាវជ្រាវ។ ចម្លើយនៃការសម្ភាសផ្ទាល់ត្រូវបានប្រមូលទិន្នន័យ ដើម្បីវិភាគ និងសិក្សាពីទស្សនរបស់គ្រូបង្រៀនចំពោះស្ថានភាពនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅកម្រិតអនុវិទ្យាល័យ។

### ៣.៤.២ កម្រងសំណួរ

អ្នកសិក្សាស្រាវជ្រាវបានធ្វើបទបង្ហាញពីប្រធានបទ និងគោលបំណងនៃការស្រាវជ្រាវទៅកាន់អ្នកចូលរួមមុនពេលដំណើរការប្រមូលទិន្នន័យ។ បន្ទាប់ពីការធ្វើបទបង្ហាញរួច អ្នកស្រាវជ្រាវ បានចែកកម្រងសំណួរជូនដល់អ្នកចូលរួមចំនួន១១៨នាក់ដើម្បីឆ្លើយសំណួរ។ ចម្លើយនៃកម្រងសំណួរដែលឆ្លើយដោយអ្នកចូលរួមត្រូវបានប្រមូលដើម្បីធ្វើការវិភាគនិងសិក្សាឈ្វេងយល់ និងសិក្សាពីបញ្ហាប្រឈមនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅកម្រិតអនុវិទ្យាល័យក្នុងខេត្តតាកែវ។

### ៣.៤.៣ កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញដែលបានប្រើប្រាស់ក្នុងកម្រងសំណួរ ដើម្បីចុះប្រមូលទិន្នន័យពីភាគីពាក់ពន្ធ័ទៅតាមការឆ្លើយតបក្នុងកម្រិតតួលេខដាក់លាក់ ដែលត្រូវបានបំពេញដោយផ្ទាល់នៅក្នុងកម្រងសំណួរលើ

ប្រធានបទនៃការស្រាវជ្រាវ។ កម្រងសំណួរសិក្សាស្រាវជ្រាវនៃប្រធានបទខាងលើត្រូវបានបែងចែកជាពីរផ្នែកគឺ៖

ផ្នែកទី១ ប្រើកម្រិតចង្អុលបង្ហាញ៤កម្រិតពី ទាបបំផុត ទៅខ្ពស់បំផុត។ តួលេខចង្អុលបង្ហាញតាមបែប Likert Scale ដើម្បីវាស់វែងសូចនាករក្នុងការវាយតម្លៃពីកម្រិតការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ។ រូបមន្តនៃកម្រិតចង្អុលបង្ហាញនៃផ្នែកទី១ មានដូចខាងក្រោម៖

១= តិចតួចបំផុត = ០%-២៥%  ២=តិចតួច = ២៦%-៥០%

៣=ច្រើនគួរសម = ៥១%-៧៥%  ៤=ច្រើន = ៧៦%-១០០%

ផ្នែកទី២ ប្រើកម្រិតចង្អុលបង្ហាញ៤កម្រិតពី ទាបបំផុត ទៅខ្ពស់បំផុត។ តួលេខចង្អុលបង្ហាញតាមបែប Likert Scale ដើម្បីវាស់វែងសូចនាករក្នុងការវាយតម្លៃពី កម្រិតពីបញ្ហាប្រឈមនៃការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ។ រូបមន្តនៃកម្រិតចង្អុលបង្ហាញនៃផ្នែកទី២ មានដូចខាងក្រោម៖

១ = ប្រឈមតិច  ២= ប្រឈមមធ្យម  ៣= ប្រឈមខ្លាំង

## ៣.៥ វិធីសាស្ត្រវិភាគទិន្នន័យ

### ៣.៥.១ ការវិភាគសម្ភាសផ្ទាល់

អ្នកសិក្សាស្រាវជ្រាវបានយកទិន្នន័យ ដែលប្រមូលបានពីការសម្ភាសន៍ផ្ទាល់ទៅធ្វើការសំអាតរៀបចំ តាមប្រភេទសំណួរ និងវិភាគបកស្រាយ។ ទិន្នន័យនៃសំណួរផ្ទាល់ត្រូវបានវិភាគ និងបកស្រាយដាក់ចូលក្នុងតារាងទិន្នន័យ។ ការវិភាគទិន្នន័យនៃកម្រងសំណួរសម្ភាសមានសារៈសំខាន់ខ្លាំងណាស់ក្នុងការសិក្សាពីទស្សនគ្រូបង្រៀន ចំពោះការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ។

### ៣.៥.២ ការវិភាគកម្រងសំណួរ

អ្នកសិក្សាស្រាវជ្រាវបានយកទិន្នន័យ ដែលប្រមូលបានពីការធ្វើកម្រងសំណួរទៅរៀបចំតាមប្រភេទ និង វិភាគបកស្រាយ។ ទិន្នន័យនៃកម្រងសំណួរត្រូវបានវិភាគ និងបកស្រាយដាក់ចូលក្នុងតារាងទិន្នន័យ។ ការវិភាគទិន្នន័យ នៃការសិក្សាស្រាវជ្រាវនេះត្រូវបានវិភាគដោយការប្រើប្រាស់វិធីសាស្ត្រវិភាគបរិមាណវិស័យ

និងបានប្រើប្រាស់កម្មវិធី Excel។ ការវិភាគទិន្នន័យនៃកម្រងសំណួរ គឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងការសិក្សា និងកម្រិតពីបញ្ហាប្រឈមរបស់គ្រូបង្រៀនក្នុងស្ថានភាពនៃការប្រតិបត្តិវិជ្ជាជីវៈ និងសិក្សាឈ្វេងយល់ពីការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅកម្រិតអនុវិទ្យាល័យ។

## ៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានរក្សាការសម្ងាត់របស់បុគ្គល និងអត្តសញ្ញាណរបស់អ្នកចូលរួមផ្តល់ការសម្ភាសន៍ និងបំពេញកម្រងសំណួរ។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំសេចក្តីអនុញ្ញាតពីអ្នកចូលរួមទាំងអស់ដើម្បីផ្តល់នូវក្រមសីលធម៌នៃការស្រាវជ្រាវដល់អ្នកចូលរួម។ បុគ្គលភាព និងអត្តសញ្ញាណរបស់អ្នកចូលរួមទាំងអស់មិនត្រូវបានលាតត្រដាងជាសាធារណៈ។ ទស្សន និងចម្លើយរបសអ្នកចូលរួមត្រូវបានធ្វើការវិភាគ និងបកស្រាយដោយការគោរពតាមក្រមសីលធម៌នៃការស្រាវជ្រាវក្នុងការសិក្សាពី (១)ទស្សនគ្រូបង្រៀនចំពោះការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ (២) ឈ្វេងយល់ពីការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ (៣) កម្រិតពីបញ្ហាប្រឈមនៃការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តតាកែវ។

# ជំពូក ៤
# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញពីលទ្ធផលនៃការវិភាគ ធ្វើការបកស្រាយលទ្ធផល និងពិភាក្សានូវអ្វីដែលបានរកឃើញតាមរយៈការសម្ភាសផ្ទាល់ និងតាមរយៈការបំពេញកម្រងសំណួរលើក្រុមគោលដៅដែលពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវពីគ្រូបង្រៀននៅសាលាអនុវិទ្យាល័យ និងសាលាវិទ្យាល័យក្នុងខេត្តតាកែវជៀបនិងទ្រឹស្តីស្រាវជ្រាវកន្លងមកដែលមាននៅក្នុងជំពូក២។ ជំពូក៤នេះ នឹងបង្ហាញពីលទ្ធផលនៃចំណុចសំខាន់ៗ ដែលឆ្លើយតបនិងសំណួរបានចោទសួរក្នុងសំណួរស្រាវជ្រាវទាក់ទងនិងទស្សនគ្រូបង្រៀនចំពោះការប្រតិបត្តិវិជ្ជាជីវៈ ឈ្វេងយល់ពីការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូបង្រៀន និងកម្រិតពីបញ្ហាប្រឈមនៃការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ។

## ៤.១ លទ្ធផលនៃការស្រាវជ្រាវ

### ៤.១.១ សិក្សាពីទស្សនគ្រូបង្រៀនចំពោះការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ

គោលបំណងនៃសំណួរស្រាវជ្រាវទី១ គឺដើម្បីសិក្សាពីទស្សនគ្រូបង្រៀនចំពោះការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ។ កម្រងសំណួរសម្ភាសដែលពាក់ព័ន្ធនិងការអនុវត្តមានសូចនាករចំនួន១២ ចំណុច។ ការវិភាគទិន្នន័យ គឺប្រើប្រាស់ការវិភាគហេតុវិនិច្ឆ័យដោយវិភាគលើខ្លឹមសារការពន្យល់បកស្រាយ និងទ្រឹស្តីមូលដ្ឋានគ្រឹះ។ លទ្ធផលក្នុងផ្នែកទី១នេះ គឺត្រូវបានបង្ហាញក្នុងតារាងខាងក្រោម៖

*តារាង ៤.១ ទស្សនគ្រូបង្រៀនចំពោះការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ*

| ខ្លឹមសារ | ចម្លើយរបស់គ្រូបង្រៀន |
|---|---|
| ១. គ្រូបង្រៀន | សំដៅលើការអប់រំសិស្សទូទៅឱ្យមានជំនាញ បំណិន ឥរិយាបថ សីលធម៌ និងចេះរស់នៅក្នុងសង្គមជាតិ |

| | |
|---|---|
| ២. វិធីសាស្ត្របង្រៀន | ជាក្បួនច្បាប់ តិចនិច ចងក្រងក្នុងការបង្រៀន និងរៀឱ្យ មានប្រសិទ្ធភាពក្នុងពេលបង្រៀន |
| ៣. ការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀន | សំដៅលើការអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវការប្រព្រឹត្តិលើការ ងារប្រចាំថ្ងៃ ទាំងការបង្ហាត់បង្រៀន ការធ្វើកិច្ចតែងការបង្រៀនរួមទាំងការដាក់លំហាត់អនុវត្តជាប្រចាំដល់សិស្ស |
| ៤. ការយល់ចំពោះពាក្យប្រតិបត្តិវិជ្ជាជីវៈ | សំដៅលើបទបញ្ញាត្តិដែលត្រូវបានកំណត់ឡើងសម្រាប់ប្រភេទវិជ្ជាជីវៈនីមួយៗដែលមានចរិកលក្ខណៈជាកម្រិត ឬតម្រូវរួមទាំងការពិន័យចំពោះអ្នកដែលបានប្រព្រឹត្តផ្ទុយមិនបានគោរពអនុវត្តវិជ្ជាជីវៈដែលខ្លួនកំពុងអនុវត្ត |
| ៥.បញ្ហាប្រឈមនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀន | ជួបបញ្ហាដូចជា កង្វះខាតសម្ភារៈឧបទេស កង្វះខាតចំណេះដឹងផ្នែកព័ត៌មានវិទ្យា សិស្សានុសិស្សមិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីទិញស្មាតហ្វូនរួមទាំងមកយឺតយ៉ាវក្នុងម៉ោងសិក្សាទាំងគ្រូ និងសិស្ស |
| ៦. តួនាទី និងភារកិច្ចគ្រូបង្រៀន | មានតួនាទី និងភារកិច្ចដូចជា ត្រៀមមេរៀន ស្រាវជ្រាវឯកសារត្រៀមនៅសំណួរចម្លើយ ធ្វើកិច្ចតែងការបង្រៀន ត្រៀមសម្ភារៈឧបទេស និងជ្រើសរើសវិធីសាស្ត្របង្រៀនមេរៀមនីមួយៗសមស្រប |
| ៧. លក្ខណៈសម្បត្តិគ្រូបង្រៀន | មានលក្ខណៈសម្បត្តិដូចជា មានចំណេះដឹងខ្ពស់ មានវិធីសាស្ត្របង្រៀនច្រើន មានអាកប្បកិរិយាសមរម្យ និងមាននិយ័តភាពការងារ |
| ៨. បញ្ញត្តិនៃការប្រតិបត្តិវិជ្ជាជីវៈ | ដូចជា គោរពពេលវេលា មានកិច្ចតែងការបង្រៀន គោរពវិន័យ និងខិតខំស្វែងរកវិធីសាស្ត្រថ្មីៗដើម្បីបង្រៀនសិស្ស |

| | |
|---|---|
| ៩. ស្ថានភាពនៃការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀន | មានស្ថានភាពដូចជា សិស្សខ្លះមិនគោរពវិន័យ សិស្សមិនផ្តល់តម្លៃលើការសិក្សា សិស្សមិនគោរពគ្រូ ខ្វះអាគារសិក្សា ខ្វះសៀវភៅគោល |
| ១០. ការប្រើប្រាស់បច្ចេកវិទ្យាបង្រៀន | ជួបបញ្ហាជាច្រើនរួមមាន សិស្សខ្សោយពិបាករៀន គ្រូបង្រៀនមានចំណេះដឹងមិនគ្រប់គ្រាន់ផ្នែកបច្ចេកវិទ្យា និងសិស្សមួយចំនួនមិនមានលទ្ធភាពទិញស្មាតហ្វូន |
| ១១. ការប្រើប្រាស់បច្ចេកវិទ្យាបង្រៀន | សំដៅលើការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិចកាន់តែទំនើបទាន់សម័យក្នុងដំណើរការបង្រៀន |
| ១២. ផលប្រយោជន៍នៃការប្រើប្រាស់បច្ចេកវិទ្យាបង្រៀន | ផ្តល់ផលប្រយោជន៍ដូចជា ចំណេញពេលវេលា គ្រូនិងសិស្សមានបំណិនលើផ្នែកបច្ចេកវិទ្យា |

តាមតារាង៤.១ លទ្ធផលនៃការស្រាវជ្រាវពី ទស្សនគ្រូបង្រៀនចំពោះការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ ដែលបានបង្ហាញអំពីសូចនាករនីមួយៗ គ្រូបង្រៀនបានឱ្យនិយមន័យថាគ្រូបង្រៀនសំដៅលើការអប់រំសិស្សទូទៅឱ្យមានជំនាញ បំណិន ឥរិយាបថ សីលធម៌ និងចេះរស់នៅក្នុងសង្គមជាតិ។ វិធីសាស្រ្តបង្រៀនជាក្បួនច្បាប់ តិចនិច ចងក្រងក្នុងការបង្រៀន និងរៀនឱ្យមានប្រសិទ្ធភាពក្នុងពេលបង្រៀន។ ក្នុងន័យនេះ វិធីសាស្រ្តបង្រៀនជាល្បិចកល ឬវិធីក្នុងការពន្យល់ណែនាំសិស្សឱ្យឆាប់ចេះ ឆាប់យល់ចំពោះមេរៀននីមួយ។ ការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀនសំដៅលើការអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវការប្រព្រឹត្តិលើការងារប្រចាំថ្ងៃ ទាំងការបង្ហាត់បង្រៀន ការធ្វើកិច្ចតែងការបង្រៀន រួមទាំងការដាក់លំហាត់អនុវត្តជាប្រចាំដល់សិស្ស។ គ្រូបង្រៀបានយល់និងឱ្យនិយមន័យទៅលើ “ពាក្យប្រតិបត្តិវិជ្ជាជីវៈ” សំដៅលើបទបញ្ញាត្តិដែលត្រូវបានកំណត់ឡើងសម្រាប់ប្រភេទវិជ្ជាជីវៈនីមួយៗ ដែលមានចរិកលក្ខណៈជាកម្រិត ឬតម្រូវ រួមទាំងការពិន័យចំពោះអ្នកដែលបានប្រព្រឹត្តផ្ទុយមិនបានគោរពអនុវត្តវិជ្ជាជីវៈដែលខ្លួនកំពុងអនុវត្ត។

តាមតារាង៤.១ គ្រូបង្រៀនបានលើកឡើងថា ការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀនជួបបញ្ហាដូចជា កង្វះ ខាតសម្ភារៈឧបទេស កង្វះខាតចំណេះដឹងផ្នែកព័ត៌មានវិទ្យា សិស្សានុសិស្សមិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីទិញស្មាតហ្វូន រួមទាំងមកយឺតយ៉ាវក្នុងម៉ោងសិក្សាទាំងគ្រូ និងសិស្ស។ គ្រូបង្រៀនមានតួនាទី និងភារកិច្ចដូចជា ត្រៀមមេរៀន ស្រាវជ្រាវឯកសារ ត្រៀមនៅសំណួរចម្លើយ ធ្វើកិច្ចតែងការបង្រៀន ត្រៀមសម្ភារៈឧបទេស និងជ្រើសរើសវិធីសាស្ត្របង្រៀនមេរៀមនីមួយៗសមស្រប។ គ្រូបង្រៀនមានលក្ខណៈសម្បត្តិដូចជា មានចំណេះដឹងខ្ពស់ មានវិធីសាស្ត្របង្រៀនច្រើន មានអាកប្បកិរិយាសមរម្យ និងមាននិយ័តភាពការងារ។ លោកគ្រូ~អ្នកគ្រូប្រតិបត្តិវិជ្ជាជីវៈរបស់ខ្លួនឱ្យសមស្របតាមបទបញ្ញត្តិដូចជា គោរពពេលវេលា មានកិច្ចតែងការបង្រៀន គោរពវិន័យ និងខិតខំស្វែងរកវិធីសាស្ត្រថ្មីៗដើម្បីបង្រៀនសិស្ស។

តាមតារាង៤.១ នេះផងដែរ គ្រូបង្រៀនបានលើកឡើងថា ការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀននៅកម្រិតអនុវិទ្យាល័យមានស្ថានភាពដូចជា សិស្សខ្លះមិនគោរពវិន័យ សិស្សមិនផ្តល់តម្លៃលើការសិក្សា សិស្សមិនគោរពគ្រូ ខ្វះអគារសិក្សា ខ្វះសៀវភៅគោល។ ការប្រើប្រាស់បច្ចេកវិទ្យាបង្រៀនជួយសិស្សរៀនកាន់តែមានប្រសិទ្ធភាពជួបបញ្ហាជាច្រើនរួមមាន សិស្សខ្សោយពិបាករៀន គ្រូបង្រៀនមានចំណេះដឹងមិនគ្រប់គ្រាន់ផ្នែកបច្ចេកវិទ្យា និងសិស្សមួយចំនួនមិនមានលទ្ធភាពទិញស្មាតហ្វូន។ ការប្រើប្រាស់បច្ចេកវិទ្យាបង្រៀនសំដៅលើការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិចកាន់តែទំនើបទាន់សម័យក្នុងដំណើរការបង្រៀន។ ការប្រើប្រាស់បច្ចេកវិទ្យាបង្រៀនផ្តល់ផលប្រយោជន៍ដូចជា ចំណេញពេលវេលា គ្រូនិងសិស្សមានបំណិនលើផ្នែកបច្ចេកវិទ្យា។ នេះសបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់បច្ចេកវិទ្យាបង្រៀនក្នុងការបង្រៀនពិតជាមានសារៈសំខាន់ខ្លាំងណាស់ព្រោះវាជួយគ្រូនិងសិស្សឱ្យមានចំណេះដឹងទូលំទូលាយផ្នែកបច្ចេកវិទ្យាដើម្បីឆ្លើយតបតាមការវិវត្តន៍របស់សកលលោក។

### ៤.១.២ សិក្សាពីកម្រិតនៃការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ




*ក្រាប៤.២៖ភាគរយនៃការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិខេត្តតាកែវចំពោះសូចនាករទី១, ២, និង៣*

តាមរយៈលទ្ធផលស្រាវជ្រាវក្រាប៤.២នៃសំណួរ 2.1 បានបង្ហាញថា គ្រូបង្រៀនមានកិច្ចតែងការបង្រៀន កម្មវិធីបង្រៀន និងវង្វាយតម្លៃស្របតាមខ្លឹមសារមេរៀនចន្លោះពី០% - ២៥% មានចំនួន ០.៨៥% ចន្លោះពី ២៦% - ៥០% មានចំនួន៨.៤៧% ចន្លោះពី៥១% - ៧៥% មានចំនួន ៣៥.៥៩% និងចន្លោះពី៧៦%-១០០% មានចំនួន៥៥.០៨% ដូចនេះ ជារួមស្ថិតនៅក្នុងកម្រិត "ច្រើនគួរសម"។ ដូចនេះលទ្ធផលបង្ហាញថា គ្រូបង្រៀនមានកិច្ចតែងការបង្រៀន កម្មវិធីបង្រៀន និងវង្វាយតម្លៃស្របតាមខ្លឹមសារមេរៀនដូចបានបង្ហាញក្នុងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនដែលបានចែងថា បង្រៀនមានកិច្ចតែងការបង្រៀន កម្មវិធីបង្រៀន និងវង្វាយតម្លៃស្របតាមខ្លឹមសារមេរៀន ។

តាមតារាងនៃសំណួរ 2.2 បានបង្ហាញថា គ្រូបង្រៀនបានរៀបចំសម្ភារឧបទេសបង្រៀននិងរៀនស្រតាមខ្លឹមសារមេរៀនចន្លោះពី០% - ២៥% មានចំនួន០.៨៥% ចន្លោះពី ២៦% - ៥០% មានចំនួន ២៣.៧៣% ចន្លោះពី៥១% - ៧៥% មានចំនួន៥១.៦៩% និងចន្លោះពី៧៦%-១០០% មានចំនួន ២៣.៧៣% ជារួមស្ថិតនៅក្នុងកម្រិត "ច្រើនគួរសម"។ ដូចនេះលទ្ធផលបង្ហាញថា គ្រូបង្រៀនមាន

រៀបចំសម្ភារឧបទេស បង្រៀននិងរៀនស្របតាមខ្លឹមសារមេរៀនដូចបានបង្ហាញក្នុងស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនដែលបានចែងថា គ្រូបង្រៀនបានរៀបចំសម្ភារឧបទេសបង្រៀននិងរៀនស្របតាមខ្លឹមសារមេរៀនប្រកបដោយប្រសិទ្ធភាព។

តារាងក្រាបនៃសំណួរ 2.3 បានបង្ហាញថា គ្រូបង្រៀនបានប្រើប្រាស់វិធីសម្បូរបែបសម្រាប់ខ្លឹមសារមេរៀន នីមួយៗចន្លោះពី០%-២៥% មានចំនួន៨.៤៧% ចន្លោះពី ២៦%-៥០% មានចំនួន១២.៧១% ចន្លោះពី៥១%-៧៥% មានចំនួន៥០.៨៥% និងចន្លោះពី៧៦%-១០០% មានចំនួន២៧.៩៧% ជារួមស្ថិតនៅក្នុងកម្រិត «ច្រើនគួរសម"។ ដូចនេះលទ្ធផលបង្ហាញថា គ្រូបង្រៀនបានប្រើប្រាស់វិធីសម្បូរបែបសម្រាប់ខ្លឹមសារមេរៀននីមួយៗដូចបានបង្ហាញក្នុងស្តង់ដា វិជ្ជាជីវៈគ្រូបង្រៀនដែលបានចែងថា គ្រូបង្រៀនបានប្រើប្រាស់វិធីសម្បូរបែបសម្រាប់ខ្លឹមសារមេរៀននីមួយៗ ប្រកបដោយប្រសិទ្ធភាពដូចបានរៀបរាប់ក្នុងតារាងក្រាប៤.២។




*ក្រាប៤.៣៖ ភាគរយនៃការប្រតិបត្តិវិជ្ជាជីវៈរបស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិខេត្តតាកែវចំពោះសូចនាករទី៤, ៥, និង៦*

